# ជម្ងឺស្លឹកប្រាក់លើដំណាំក្រូចពោធិសាត់

**ដោយតាំងប៊ុនស៊ុយ**

ជម្ងឺស្លឹកប្រាក់ធ្វើឲ្យដើមក្រូចលូតលាស់យឺតខុសពីធម្មតាស្លឹកចេញពណ៌លឿងពព្លិចពព្លាក់ក្រូចផ្កាខុសរដូវផ្លែតូចរស់ជាតិមិនឆ្ងាញ់ជ្រុះមុនទុំ។

ជម្ងឺនេះបណ្តាលមកពីបាក់តេរីCandidatus Liberobacter asiaticusចម្លងពីដើម១ទៅដើម១ដោយសត្វល្អិតDiaphorina citri(DC)។

គេបានរកឃើញជម្ងឺស្លឹកប្រាក់មុនគេនៅប្រទេសចិនក្នុងឆ្នាំ១៨៩៤។បន្ទាប់មកជម្ងឺបានរាលដាលដល់ទ្វីបអាមេរិកនិងអាហ្វ្រិក។
នៅឥណ្ឌូចិនវាបានកើតនៅប្រទេសវៀតណាមនៅឆ្នាំ១៩៦០នៅប្រទេសថៃឆ្នាំ១៩៧៣នៅប្រទេសខ្មែរឆ្នាំ១៩៨២។
ទឹកជំនន់ស្ទឹងសង្កែបីដងក្នុងឆ្នាំ១៩៩៣បានធ្វើឲ្យជម្ងឺនេះផ្ទុះយ៉ាងខ្លាំងនៅស្រុកបាណន់ដែលជាហេតុធ្វើឲ្យផ្ទៃដីដាំក្រូចពោធិ៍សាត់ស្រុតចុះជាបន្តបន្ទាប់រហូតមកដល់ពេលនេះ។
ដោយគ្មានវិធានការព្យាបាលអ្នកស្រុកអស់សង្ឃឹមក្នុងមុខរបរដាំក្រូចពោធិសាត់។

ក្រូចពោធិសាត់ចាប់ផ្លែ៤ឆ្នាំក្រោយពេលដាំ ហើយផ្លែច្រើនរស់ជាតិឆ្ងាញ់បំផុតឆ្នាំទី៨-ទី៩។បន្ទាប់មកផ្លែចុះថយរហូតឆ្នាំទី១២ឬ១៣។

ក្រូចឈឺរស់បានយ៉ាងយូរ៧ឆ្នាំផ្លែតិចជាងដើមឥតឈឺដូច្នេះជម្ងឺបានធ្វើឲ្យខាតបង់ប្រាក់ចំណូលយ៉ាងធ្ងន់ធ្ងរ។

<u>លក្ខណពិសេសរបស់មេរោគដែលធ្វើឲ្យជម្ងឺពិបាកព្យាបាល</u>

១.មេរោគដែលបានចូលក្នុងស្លឹកក្រូចតាមរយៈសត្វល្អិតDCទៅពួនក្នុងបំពង់បង្ហូរជ័រក្រោមសំបក(Liber)

២.មុនពេលចេញរោគសញ្ញាគេមិនដឹងថាដើមក្រូចឈឺទេព្រោះមេរោគដែលបានចូលក្នុងស្លឹកត្រូវការពេលពី៦ខែទៅ១ឆ្នាំមុននិងបង្ហាញរោគសញ្ញា។រយៈពេលនេះអាចកើនឡើងទៅ៣-៤ឆ្នាំបើចំការបានទទួលជីទឹកស្រោចស្រពនិងការថែទាំជិតដល់។ដូច្នេះអ្នកផ្សាំនិងអ្នកបំបៅយកមែកទៅប្រើស្មានថាមែកនោះឥតផ្ទុកមេរោគទេព្រោះពុំឃើញរោគសញ្ញា។

៣.ដើមក្រូចដែលបានផ្ទុកមេរោគក្នុងដើមមិនបង្ហាញរោគសញ្ញាគ្រប់មែកទេដំបូងចេញ

លើមែកតូចតែមួយបន្ទាប់មកចេញលើមែក២ឬ៣ចំណែកមែកឯទៀតដុះលូតលាស់ធម្មតាតែបានផ្ទុកមេរោគរួចស្រេចទៅហើយ។បើយើងយកមែកនោះទៅផ្សាំ (layering) ឬទៅបង្កាត់ (graphting) យើងធ្វើឲ្យជម្ងឺសាយភាយទៅចំការថ្មី។

៤.ឯចំណែកដើមក្រូចដែលនៅជុំវិញដើមឈើថ្មីបើគ្មានរោគសញ្ញាអាចផ្ទុកមេរោគ រួចស្រេចដែរ។ពីព្រោះសត្វល្អិតDCទាក់ទាញដោយពណ៌លឿងនៃស្លឹកប្រាក់មកជញ្ជក់ជ័រស្លឹកប្រាក់ដែលផ្ទុកមេរោគ។ពេលវានឹងហើរទៅទិចត្រួយខ្ចីរបស់ដើមជិតខាងវានឹងនាំមេរោគទៅឆ្លងដើមនោះ។អ្នកផ្សាំឬបង្កាត់ឃើញដើមជិតខាងដើមឈឺឥតមានរោគសញ្ញាក៏យកមែកវាទៅប្រើសំរាប់ផ្សាំឬបង្កាត់ដែលជាហេតុធ្វើឲ្យមេរោគឆ្លងទៅចំការថ្មី។

៥. បើរោគសញ្ញាក្រចេញដើមក្រូចថ្មី បើផ្ទុកមេរោគក្រងាប់ផ្លែបានយូរជាងដើមក្រូចមាន រោគសញ្ញា២ទៅ៣ឆ្នាំ។ដូច្នេះការដាក់ជីស្រោចទឹកបាញ់ថ្នាំសុទ្ធសឹងជាវិធានការគួរយកទៅអនុវត្តន៍ព្រោះធ្វើឲ្យដើមក្រូចរឹងមាំស៊ូនិងជម្ងឺបានមួយរយៈ។

<u>វិធានការដែលត្រូវអនុវត្តន៍</u>

ក្នុងស្ថានការណ៍សព្វថ្ងៃដែលជម្ងឺរាលដាលពេញស្រុកបាណន់និងស្រុកសង្កែយើងអាចសន្និដ្ឋានថាដើមក្រូចពោធិសាត់ទាំងអស់បានផ្ទុកមេរោគថ្វីបើដើមក្រូចខ្លះមិនទាន់បង្ហាញរោគសញ្ញា។

ដើម្បីកុំឲ្យរោគសញ្ញាឆាប់ចេញដែលអនុញ្ញាតឲ្យពន្យាពេលផលិតបាន២-៣ឆ្នាំយើងគួរ

- ធ្វើយ៉ាងណាឲ្យដើមរឹងមាំដោយដាក់ជីស្រោចទឹកថែទាំចំការឲ្យបានត្រឹមត្រូវ
- កាត់មែកមានរោគសញ្ញាដំបូងឬគាស់ដើមទាំងមូលជាមួយឬសយកទៅដុតចោល។
- បាញ់ថ្នាំកំចាត់សត្វDC។តាមឯកសារដែលយើងបានស្រាវជ្រាវដើម្បីជៀសវាងថ្នាំគីមីយើងអាចប្រើថ្នាំជក់ដែលត្រូវរៀបចំឡើងតាមរូបមន្តជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ។
- ដាំដើមត្របែកចន្លោះរងក្រូច។

<u>ព្រឹត្តការណ៍ដែរបានកើតឡើងនៅបាត់ដំបងបានផ្តល់មេរៀនដូចតទៅៈ</u>

១.ទឹកលិចឆ្នាំ១៩៩៣បានធ្វើឲ្យជម្ងឺផ្ទុះយ៉ាងខ្លាំង។នេះបញ្ជាក់ឲ្យឃើញថារោគសញ្ញាបានលិចផ្លោ យ៉ាងឆាប់រហ័សលើដើមដែលចុះខ្សោយដោយសារទឹកលិច។

២. ផ្ទុយទៅវិញការដាក់ជីស្រោចទឹក(ប្រយ័ត្នកុំឲ្យដីជាំទឹក)បាញ់ថ្នាំធ្វើឲ្យដើមរឹងមាំរោគ សញ្ញាក្រ ចេញដូច្នេះដំណាំអាចផលិតផ្លែក្រូចបានយូរជាងចំការឯទៀត។

៣. ការដាំញឹកមិនមែនជាមធ្យោបាយគួរឲ្យយកមកប្រើទេព្រោះវាធ្វើឲ្យជម្ងឺរាល ដាលឆាប់រហ័សពេញចំការ។

## ការសន្និដ្ឋាន

ក្រោយពីយើងបានសន្ទនាជាមួយព្រឹទ្ធបុរសមហាវិទ្យាល័យកសិកម្មបាត់ដំបងយើងបានដឹងថាលោកមានបច្ចេកទេសអនុញ្ញាតឲ្យយើងដឹងថាដើមក្រូចផ្ទុកជម្ងឺឬមិនផ្ទុកថ្វីបើគ្មានរោគសញ្ញា។

ដូច្នេះយើងមិនទាន់អស់សង្ឃឹមទេចំពោះដំណោះស្រាយបញ្ហាជម្ងឺស្លឹកប្រាក់យើងសូមស្នើឲ្យរៀបចំ សិក្ខាសាលាដើម្បីឲ្យសហគមន៍ដាំក្រូច មន្ទីរកសិកម្មបាត់ដំបង និងតំណាងសាកលវិទ្យាល័យបាត់ដំបងបានជួបគ្នាប្តូរបទពិសោធន៍ចំណេះដឹងដើម្បីរិះរកវិធីសាស្ត្រថ្មីកាត់បន្ថយជម្ងឺស្លឹកប្រាក់ហើយធានានិរន្តភាពរបស់ក្រូចពោធិសាត់នៅបាត់ដំបង។

## ឧបសម្ពន្ធ

ការស្រាវជ្រាវឯកសារបានឲ្យដឹងថាជាតិNicotineដែលមានក្នុងថ្នាំជក់អាចសម្លាប់សត្វល្អិតDC។

+ វត្ថុធាតុដើម:

. ថ្នាំជក់ខ្លាំង១គីឡូ

. ទឹក១០លីត្រ

+ របៀបផលិត:

.ចិញ្រ្ចាំថ្នាំជក់ឲ្យល្អិតហើយយកទៅត្រាំទឹកក្តៅឧណ្ហៗតាមអត្រាខាងលើរយ:ពេល១២ម៉ោងរួចពូតយកកាកថ្នាំចេញដើម្បីយកទឹកថ្នាំទៅប្រើ។

.ដើម្បីទុកប្រើបានយូរ(៣-៤ខែ) ថែមកំបោរស៧ក្រាមក្នុង ទឹកថ្នាំជក់១លីត្រ ទុកពេលឲ្យកំបោររលាយ២ទៅ៣ម៉ោងហើយចម្រាញ់យកកាកកំបោរចេញឲ្យអស់។

+របៀបប្រើ:ទឹកថ្នាំជក់២លីត្រ + ទឹកធម្មតា៨លីត្រលាយនឹងម្សៅសាប៊ូ២០ក្រាម កូរឲ្យរលាយចូលគ្នា។

- មុននឹងចាក់ក្នុងបំពង់បាញ់ថ្នាំត្រូវក្រឡុកធុងសិន។
- បាញ់ពេលល្ងាច